ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមការងារចុះមូលដ្ឋាន
ខេត្តក្រចេះ

## សូមជម្រាបជូន

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាប្រធាន អនុប្រធាន និងសមាជិកក្រុមការងារ ចុះមូលដ្ឋានស្រុក ក្រុង ទាំង៦ នៃខេត្តក្រចេះ**

**កម្មវត្ថុៈ** ស្តីពីការរៀបចំប្រគេនទៀនព្រះវស្សានៅតាមវត្តទាំង១៧២ ស្ថិតក្នុងស្រុក ក្រុង ទាំង៦ នៃខេត្តក្រចេះ។
**យោង** ៖ ការឯកភាពជាមួយ **ឯកឧត្តម វ៉ា ថន** ប្រធានគណៈកម្មាធិការបក្ស និងជាអភិបាលខេត្តក្រចេះ។

តាមកម្មវត្ថុ និងយោងខាងលើ ដើម្បីរួមចំណែកជាមួយពុទ្ធបរិស័ទចំណុះជើងវត្ត និងប្រជាពលរដ្ឋ តាមមូលដ្ឋាន ភូមិ ឃុំ សង្កាត់នីមួយៗ ចូលរួមគោរពប្រណិប័តន៍តាមប្រពៃណីព្រះពុទ្ធសាសនាក្នុងឱកាសបុណ្យចូលព្រះវស្សា នាថ្ងៃ១រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ ខាងមុខនេះ ខ្ញុំសូមអំពាវនាវឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងសប្បុរសជនទាំងអស់ មេត្តារួមសាមគ្គីគ្នាដើម្បីរៀបចំការប្រគេនទៀនព្រះវស្សាតាមវត្តទាំងអស់ទាំង១៧២វត្ត ក្នុងខេត្តក្រចេះ ទៅតាមមូលដ្ឋានស្រុក ក្រុងរៀងៗខ្លួន។

អាស្រ័យហេតុនេះ ខ្ញុំសូមស្នើឯកឧត្តម លោកជំទាវ ប្រធាន អនុប្រធានក្រុមការងារស្រុក ក្រុង នីមួយៗ មេត្តារួមគ្នាក្នុងក្រុមដើម្បីម្ចាស់ការចាត់ចែងរៀបចំទៀនព្រះវស្សា ទេយ្យវត្ថុ និងសំភារៈ ថវិកាចាំបាច់មួយចំនួនសម្រាប់ប្រារព្ធពិធីប្រគេនទៀនព្រះវស្សាតាមវត្តទាំងអស់ស្ថិតក្នុងមូលដ្ឋាន ដែលឯកឧត្តម លោកជំទាវទទួលខុសត្រូវ ឱ្យបានសមស្រប និងទាន់ពេលវេលាកំណត់ នៃថ្ងៃបុណ្យចូលព្រះវស្សាប្រចាំឆ្នាំ។

ចំពោះរូបភាព កម្មវិធី និងកាលបរិច្ឆេទ នៃការប្រារព្ធពិធីបុណ្យខាងលើនេះ គឺអាស្រ័យដោយការកំណត់សម្រេចរបស់ក្រុមការងារស្រុក ក្រុង នីមួយៗ ហើយត្រូវរក្សាឱ្យបានសុវត្ថិភាព ដោយអនុវត្តវិធានការ "៣ការពារ និង ៣កុំ" ដើម្បីប្រយុទ្ធទប់ស្កាត់ជំងឺកូវីដ-១៩។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងសប្បុរសជនទាំងអស់ មេត្តាជ្រាប និងចូលរួមពិធីបុណ្យឱ្យបានច្រើនកុះករដើម្បីទទួលបានមគ្គផលកុសលផលបុណ្យទៅតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។

សូម ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងសប្បុរសជនទាំងអស់ មេត្តាទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅបំផុតពីខ្ញុំ។

ថ្ងៃ ព្រហស្បតិ៍ ៧រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ២០២១
**ប្រធានក្រុមការងារចុះមូលដ្ឋានខេត្តក្រចេះ**

**ហ៊ុំ សុខា**